**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១៨៧៧ ព.ណ.ស.វ.ពក

ថ្ងៃអង្គារ ៦កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាពាណិជ្ជករ និងសាធារណជនទូទៅឱ្យបានជ្រាបថា ក្រុមប្រឹក្សាជំរុញការនាំចេញវាយនភណ្ឌឥណ្ឌា គាំទ្រដោយក្រសួងវាយនភណ្ឌនៃរដ្ឋាភិបាលឥណ្ឌា នឹងរៀបចំពិព័រណ៍ "BHARAT TEX 2026" ពីថ្ងៃទី១៤-១៧ ខែកក្កដា ឆ្នាំ២០២៦ នៅទីក្រុងញូវដេលី ប្រទេសឥណ្ឌា។ ព្រឹត្តិការណ៍ពិព័រណ៍នេះផ្តោតសំខាន់លើវត្ថុធាតុដើមវាយនភណ្ឌ, អំបោះ, សម្ភារៈប្រើប្រាស់ក្នុងផ្ទះធ្វើពីក្រណាត់, វាយនភណ្ឌបច្ចេកទេស, សម្លៀកបំពាក់និងម៉ូដ, ម៉ាស៊ីននិងគ្រឿងបរិក្ខារ, សារធាតុពណ៌និងសារធាតុគីមី, វាយនភណ្ឌប្រកបដោយនិរន្តរភាព, និងសម្លៀកបំពាក់បន្ទាប់បន្សំបម្រើឱ្យវិស័យវាយនភណ្ឌ។ ចំពោះអ្នកបញ្ជាទិញ និងអ្នកនាំចូល គណៈកម្មការរៀបចំពិព័រណ៍ នឹងផ្តល់ជូនការស្នាក់នៅរយៈពេល ៣យប់ ការធ្វើដំណើរទៅ-មក ពីព្រលានយន្តហោះទៅសណ្ឋាគារ ការធ្វើដំណើរទៅ-មកពីសណ្ឋាគារទៅទីកន្លែងតាំងពិព័រណ៍ និងការអញ្ជើញចូលរួមកម្មវិធីសំខាន់ៗនៃព្រឹត្តិការណ៍ពិព័រណ៍។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមជាអ្នកសម្របសម្រួល សូមអញ្ជើញ លោក-លោកស្រី ជាពាណិជ្ជករ និងសាធារណជនទូទៅ ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងព្រឹត្តិការណ៍ខាងលើ សូមធ្វើការទំនាក់ទំនងមកបំពេញបែបបទចូលរួម តាមរយៈនាយកដ្ឋានជំរុញពាណិជ្ជកម្ម និងកិច្ចការពិព័រណ៍ អគ្គនាយកដ្ឋានគោលនយោបាយ និងជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ដែលមានអាសយដ្ឋានឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកមន្ត្រីសម្របសម្រួល តាមរយៈទូរស័ព្ទលេខ +៨៥៥ ៨៦ ៣៣៣ ៩៣៣ / +៨៥៥ ៧៧ ៣៦១ ៨៣៦ ឬអ៊ីម៉ែល sorn.pitou@moc.gov.kh / oun.veasna@moc.gov.kh ឬតាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ១២៦៦៕

**សូមអរគុណ!**

សម្រាប់ចុះឈ្មោះ

# KINGDOM OF CAMBODIA

**Nation - Religion - King**

**Ministry of Commerce**

N°.1377...MOC.D/.TPEA

Phnom Penh, 02, June, 2026

## ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform all traders and the public that the Indian Textile Export Promotion Council, supported by the Ministry of Textiles, Government of India, is going to organize **"BHARAT TEX 2026"** from 14-17 July 2026 in New Delhi, India. The Expo focuses on textile raw materials, yarns and threads, home textiles, technical textiles, apparel and fashion, machinery and equipment, dyes and chemicals, sustainable textiles, and fashion accessories. The organizer will offer overseas selected buyers and importers a complimentary three-night hotel stay, airport and venue transportation ( to and from ), transfers from hotel to the venue and return, and special invites to important events during the fair.

In this regard, the Ministry of Commerce, as a facilitator, would like to cordially invite all Cambodian traders and the public who are interested in the aforementioned event to kindly register with the Department of Trade Promotion and Exhibition Affairs, Directorate-General of Trade Policy and Promotion, Ministry of Commerce at Lot No. 19-61, Russian Federation Blvd., Phum Trung Moan, Sangkat Ou Baek K'am, Khan Sen Sok, Phnom Penh, or officials in charge via:

Tel: +855 86 333 933 / +855 77 361 836

MOC Call Center: 1266

E-mail: sorn.pitou@moc.gov.kh / oun.veasna@moc.gov.kh

THANK YOU!

For Registration